# នួន ជា រៀបរាប់ឈ្មោះអ្នកនយោបាយកម្ពុជាថា ធ្លាប់ជាអតីតកម្មាភិបាលខ្មែរក្រហម

**ដោយ វ៉េនឌល ឌីហ្វាល់កូ**

**ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២**

*ប្រែសម្រួលដោយ ជា ផល្លា*

នៅថ្ងៃអង្គារ ទី៣១ ខែមករា ឆ្នាំ២០១២នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់បន្តនូវដំណើរការសវនាការ ។ កាលវិភាគសម្រាប់ថ្ងៃនេះ គឺត្រូវបន្តសក្ខីកម្មរបស់ជនជាប់ចោទ នួន ជា ទាក់ទងទៅនឹងប្រវត្តិកំណើតកំណើតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ចៅក្រម និល ណុន ចាប់ផ្តើមដោយជូនដំណឹងទៅភាគីទាំងអស់សម្រាប់សប្តាហ៍នេះដោយបញ្ជាក់ថា នៅថ្ងៃស្អែកនេះ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ នឹងមកធ្វើសក្ខីកម្មនៅក្នុងអង្គជំនុំជម្រះ ។

## ភាគីដើមបណ្តឹងរដ្ឋប្បវេណីសួរទៅ នួន ជា

ក្រោយពីពិភាក្សាគ្នារួចទាក់ទងទៅនឹងការកំណត់ពេលវេលានៃការតាំងសំណួរដើម្បីសួរទៅលោក ឆាំង យុ អង្គជំនុំជម្រះបានប្រគល់តួនាទីនេះទៅភាគីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសួរទៅជនជាប់ចោទ នួន ជា ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស៊ឹម ស៊ីវ៉ន ចាប់ផ្តើមសួរសំណួរ ។ នៅពេលដែល ស៊ីវ៉ន សួរទៅ នួន ជា ដោយយឺតៗ និងសាមញ្ញនោះ នួន ជា ហាក់បីដូចជាធុញទ្រាន់ ហើយគាត់បានឆ្លើយតបដោយយឺតៗដែរ ដោយមើលទៅហាក់បីដូចជាធុញទ្រាន់ទៅនឹងអ្វីដែល ស៊ីវ៉ន បានធ្វើ ។ នួន ជា បានធ្វើត្រាប់តាម ស៊ីវ៉ន ដែលនិយាយយឺតៗពេកគួរឲ្យធុញ ហើយការដែល នួន ជា ធ្វើត្រាប់តាមដូច្នេះ អ្នកចូលរួមដំណើរការតុលាការនេះបានសើចដែរ ។

បន្ទាប់មក ស៊ីវ៉ន ចាប់ផ្តើមសួរទៅ នួន ជា អំពីពេលដែលគាត់រៀននៅប្រទេសថៃ ។ នួន ជា បានឆ្លើយថា គាត់បានបោះបង់ចោលការសិក្សាក្រោយពីរៀននៅសាកលវិទ្យាល័យនៅប្រទេសថៃបានមួយឆ្នាំដើម្បីចូលជាមួយចលនាតស៊ូកុម្មុយនីស្ត ។ នួន ជា និយាយថា បើសិនជាគាត់បញ្ចប់ការសិក្សា គាត់នឹងចូលមកធ្វើការបម្រើរដ្ឋ ដូច្នេះគាត់ក៏ឈប់រៀនដើម្បីចូលបដិវត្តន៍វិញ ។ គ្រាប់ពូជនៃបដិវត្តន៍ចាប់ផ្តើមដុះឬសពេលដែលគាត់មានអាយុ១៤-១៥ឆ្នាំ គាត់បានឃើញដោយផ្ទាល់ភ្នែកនូវការ«ធ្វើបាបដូចសត្វធាតុ» មកលើប្រជាកសិករខ្មែរពីសំណាក់អ្នកមានអំណាច និងអជ្ញាធរក្នុងសម័យអាណានិគម

និយមបារាំង ។ ក្រោយមក គាត់បានទៅរៀនពី«របៀបរបបថៃ» និងបានចាប់អារម្មណ៍យ៉ាងខ្លាំងពីរបៀបដែលជនកុម្មុយនីស្តជួយដល់អ្នកក្រីក្រ ។

សំណួរបន្តទៅ នួន ជា គឺអំពីដំណើរការដែលជនកុម្មុយនីស្តកម្ពុជាប្រើមធ្យោបាយដើម្បីអប់រំមហាជន ។ នួន ជា បានឲ្យដឹងថា កាលពីដំបូង វៀតណាមជាផ្តល់សម្ភារៈសម្រាប់ការអប់រំហើយ វៀតណាមក៏បានផ្តល់ទីប្រឹក្សាដែលចេះនិយាយភាសាខ្មែរ មកជួយក្នុងការបណ្តុះបណ្តាលនេះដែរ ។ កាលនោះ កម្ពុជាគឺជាផ្នែកមួយនៃចលនាបក្សកុម្មុយនីស្តឥណ្ឌូចិនដែលរួមមាន កម្ពុជា ឡាវ និង វៀតណាម ។

នួន ជា បន្តថា ក្រោយមកគាត់បានចូលជាមួយបក្សកុម្មុយនីស្តថៃ ព្រមទាំងបានទទួលការអនុញ្ញាតឲ្យត្រលប់មកកម្ពុជាវិញដើម្បីធ្វើសកម្មភាពប្រឆាំងនឹងអាណានិគមបារាំង ។ កាលនោះ គាត់ត្រលប់មកប្រទេសកម្ពុជាតែម្នាក់ឯងប៉ុណ្ណោះ ។ ពេលដែលគាត់មកដល់ប្រទេសកម្ពុជា គាត់បានផ្តាច់ទំនាក់ទំនងជាមួយកុម្មុយនីស្តថៃ រួចចូលជាមួយបក្សកុម្មុយនីស្តឥណ្ឌូចិនវិញ ។ ក្រោយសន្និសីទក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ បក្សកុម្មុយនីស្តរបស់កម្ពុជាមានចំនួនសមាជិកតិចតួចប៉ុណ្ណោះនៅសេសសល់ ។ គាត់ និងសមាជិករបស់គាត់មួយចំនួនតូចចាប់ផ្តើមរៀបចំការតស៊ូក្នុងព្រៃ និងចាប់ផ្តើមទាក់ទងជាមួយកសិករក្រីក្រដើម្បីបង្កើតបណ្តាញ ។

ក្រោយមក ស៊ីវ៉ន បានសួរ នួន ជា ទាក់ទងទៅនឹងសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការបង្កើតការតស៊ូប្រដាប់អាវុធក្នុងឆ្នាំ១៩៦៧ ។ នួន ជា បានឆ្លើយដូចមុនដែរដោយបកស្រាយថា ក្រោយសមាជបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ១៩៦២ បក្សបានបង្កើតគោលនយោបាយតស៊ូប្រដាប់អាវុធ តែការតស៊ូនយោបាយនៅតែជាអទិភាពដដែល ។ កាលនោះ មេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាគឺ មានរូបគាត់ ប៉ុល ពត និង ទូ សាមុត ។ នៅពេលសួរថា តើមេដឹកនាំជួយឧបត្ថម្ភខ្លួនដោយរបៀបណា? នួន ជា បានឲ្យដឹងថា គាត់ទទួលបានការជួយផ្តល់ម្ហូបអាហារពីកសិករ និងតាមរយៈការបរបាញ់សត្វព្រៃដើម្បីចិញ្ចឹមជីវិត ។ បក្សកុម្មុយនីស្តកម្ពុជាមិនបានបង្កើតគោលនយោបាយដើម្បីប្រឆាំងនឹងរបប សីហនុ ដែលជាប្រមុខរដ្ឋ និងជាបុគ្គលដ៏មានអំណាចជាទីបំផុតនោះទេ ។

មេធាវីបានសួរទៀតថា តើមនុស្សប្រភេទណាដែលត្រូវបានចាត់ទុកថាជា«សត្រូវ»ដោយបក្សកុម្មុយនីស្តកម្ពុជា ។ នួន ជា ឆ្លើយថា ជនបរទេសដែលមានបំណង«លេបទឹកដីកម្ពុជា» និង«ម្ចាស់ដីសក្តិភូមិ»ព្រមទាំង«បរិវារ»ត្រូវបានចាត់ទុកជាសត្រូវ ។ ទាក់ទងទៅនឹងពាក្យ «វណ្ណៈស្អាតស្អំ»វិញ នួន ជា បាននិយាយថា ពាក្យនេះគឺមានតែ«ទ្រឹស្តី»តែប៉ុណ្ណោះ បក្សកុម្មុយនីស្តកើតឡើងដោយបុគ្គលជាច្រើនរូបមានទាំងអ្នកស្អាតស្អំ និងអ្នកមិនស្អាតស្អំផង ។ នួន ជា បាននិយាយទៀតថា ប៉ុល ពត បាន

ធ្វើដំណើរទៅទីក្រុងប៉េកាំង ប្រទេសចិនក្នុងឆ្នាំ១៩៦៥ ដោយយកទៅជាមួយនូវឯកសារគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីណែនាំដល់ចលនាកុម្មុយនីស្តរបស់ចិន ។ បក្សកុម្មុយនីស្តកម្ពុជា "មិនដែល" ទទួលបានការជួយឧបត្ថម្ភថវិការពីវៀតណាមទាល់តែសោះ ។ ក្រោយមក ស៊ីវ៉ន បានបញ្ចប់សំណួរ ហើយគាត់បានប្រគល់ឱកាសនេះទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតឈ្មោះ បាណាបេ ណេគូអ៊ី សួរបន្ត ។ បាណាបេ ណេគូអ៊ី បានសួរទៅ នួន ជា ថា តើបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងតំបន់រំដោះដោយរបៀបណាបើកាលនោះមិនមានការប្រើប្រាស់លុយផងនោះ ។ នួន ជា បានឆ្លើយថា ចលនាខ្មែរក្រហមនៅពេលនោះ "មិនមានគម្រោងលុបបំបាត់លុយកាក់" ទេ តែកងទ័ពអាកាសរបស់សហរដ្ឋអាមេរិកបានបំផ្លាញលទ្ធភាពរបស់បក្សក្នុងការលក់ទំនិញផ្សេងៗបាន ។ ហេតុដូច្នេះហើយទើបបក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់ប្រព័ន្ធដោះដូរ និងបង្កើតការធ្វើស្រែប្រវាស់ដៃដើម្បីដោះស្រាយបញ្ហាម្ហូបអាហារឲ្យមានប្រសិទ្ធភាព ។ នៅកន្លែងណាដែលមានការប្រើប្រាស់លុយ សហរដ្ឋអាមេរិក និងវៀតណាមបានប្រើប្រាស់លុយកាក់ដើម្បី "អូសទាញ" កម្មាភិបាលខ្មែរក្រហមឲ្យក្បត់បដិវត្តន៍ ។ ដូច្នេះការដែលនៅប្រើប្រាស់លុយបន្តទៀត "គឺជាការគ្រោះថ្នាក់ដល់តំបន់រំដោះខ្លាំងណាស់" សូម្បីតែមនុស្សដែលមានបំណងល្អក៏អាចត្រូវបានពុករលួយដោយសារលុយដែរ ។ បក្សកុម្មុយនីស្តកម្ពុជាមិនពេញចិត្តទៅនឹងការចងការប្រាក់ចំនួន "៥០សេន" ដោយម្ចាស់ដីនិងម្ចាស់បំណុលកាលពីមុនរបបខ្មែរក្រហមទេ ។ កសិករគ្រាន់តែ "ធ្វើការបម្រើអ្នកមានប៉ុណ្ណោះ" នៅពេលនោះ ។

បាណាបេ ណេគូអ៊ី បានបន្តសំណួរទៅ នួន ជា អំពីប្រព័ន្ធទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងតំណាងរបស់បក្សកុម្មុយនីស្តវៀតណាមទាក់ទងទៅនឹងការមិនស្របគ្នានេះ ។ នួន ជា បានបញ្ជាក់ថា គាត់បានជួបជាមួយថ្នាក់ដឹកនាំវៀតណាមជាច្រើននាក់ ហើយ ប៉ុល ពត បានណែនាំគាត់ឲ្យ "បន្ថយ" ទំនាក់ទំនងជាមួយវៀតណាម ។ ប្រជាជនកម្ពុជាមិនចូលចិត្តទាហានយៀកកុងដែលចូលមកតាំងទីលំនៅលើទឹកដីខ្មែរទេ កាលពីអំឡុងសង្គ្រាមវៀតណាម ព្រោះទាហានទាំងនេះមិនបានផ្តល់ប្រយោជន៍អ្វីទាំងអស់សម្រាប់ខ្មែរ ។ វៀតណាមមិនបានហាមប្រាមទាហានដែលខ្វះសីលធម៌របស់ខ្លួនក្នុងការដែលប្រព្រឹត្តិអំពើមិនគប្បីនៅប្រទេសកម្ពុជាទេ ហើយ នួន ជា បានហៅមេដឹកនាំវៀតណាមថា "មាត់និយាយផ្សេង ចិត្តគិតផ្សេង" ។

ក្រោយមក នួន ជា បាននិយាយពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងទៅនឹង "សក្តិភូមិព្រៃផ្សៃ" ដោយគាត់បានបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាមិនបានលុបបំបាត់វណ្ណៈរបស់មនុស្សទេ តែបក្សចង់បង្ខំអ្នកទាំងនោះឲ្យបញ្ចុះការប្រាក់ឲ្យនៅកម្រិតទាបចំពោះកម្មករ កសិករ ។

បាណាបេ ណេគូអី បានសួរទៅ នួន ជា ថាតើប្រជាជនអាចធ្វើដំណើរចេញពីសហករណ៍តាមតែចិត្តបានដែរឬទេបើសិនជាអ្នកទាំងនោះចង់ទៅ? នួន ជា មិនបានឆ្លើយចំសំណួរទេ តែគាត់និយាយថា គ្មាននរណាអាចចាកចេញពីសហករណ៍បានទេ ។ លុយអាចនឹងយកទៅប្រើប្រាស់ដើម្បីទិញទំនិញពីប្រទេសថៃ កាលពីពេលដែលបក្សកុម្មុយនីស្តកម្ពុជាតាំងមូលដ្ឋាននៅក្បែរព្រំដែនថៃ ។

ប្រធានបទបន្ទាប់ គឺទាក់ទងទៅនឹងការបែងចែកប្រជាជនជាប្រជាជន«ថ្មី» និង«អ្នកមូលដ្ឋាន» ។ នួន ជា បានឆ្លើយថា ប្រជាជន«ថ្មី» គឺសំដៅទៅលើអ្នកជម្លៀស ចំណែកប្រជាជន«មូលដ្ឋាន» គឺចង់សំដៅទៅលើអ្នកដែលរស់នៅជនបទ ។ បក្សកុម្មុយនីស្តកម្ពុជាណែនាំដល់កម្មាភិបាលមូលដ្ឋានថា កុំរើសអើងនឹងប្រជាជនថ្មី ព្រោះអ្នកទាំងនោះក៏ជាខ្មែរដែរ តែកម្មាភិបាល«សមាសភាពមិនល្អ»ខ្លះបង្កជម្លោះរវាងប្រជាជនថ្មី និងអ្នកមូលដ្ឋាន ។

## បញ្ហាបច្ចេកទេសមួយចំនួន និង អៀង សារី ចង់ទៅសម្រាកតាមកាលវិភាគ

មកដល់ចំនុចនេះ បញ្ហាបកប្រែជួបប្រទះនូវបញ្ហាបច្ចេកទេស ។ បញ្ហាត្រូវបានដោះស្រាយហើយភ្លាមៗ អង្គជំនុំជម្រះបានប្រកាសសម្រាកនៅពេលព្រឹក ។ ដូចរាល់ដងដែរមុននឹងសម្រាកមេធាវីរបស់ អៀង សារី បានឡើងនិយាយថា អៀង សារី សុំលះបង់សិទ្ធិក្នុងការមានវត្តមាននៅក្នុងតុលាការដោយបញ្ហាសុខភាព និងឈឺខ្នង ។ ប្រធានអង្គជំនុំជម្រះ និល ណុន យល់ព្រម និងស្នើឲ្យជនជាប់ចោទប្រគល់លិខិតសុំជាលាយលក្ខណ៍អក្សរ ។

## ដើមបណ្ដឹងរដ្ឋប្បវេណីសួរសំណួរបន្ត

ក្រោយពីសម្រាករួច បាណាបេ ណេគូអី បានបន្តសំណួរទៅកាន់ នួន ជា អំពីជីវិតរស់នៅក្នុងសហករណ៍ក្នុងរបបខ្មែរក្រហម ។ នួន ជា បាននិយាយថា ក្នុងអំឡុងសង្គ្រាមជាមួយ លន់ លន់ គាត់បានណែនាំអប់រំប្រជាជនឲ្យចេះជួយគ្នាទៅវិញទៅមក និងចងគ្នាជាជាតិខ្មែរតែមួយ ។

បាណាបេ ណេគូអី បានសួរថា តើនរណាដែលខ្មែរក្រហមចាត់ទុកថាជា«មនុស្សល្អ»? នួន ជា បានឆ្លើយថា កសិករត្រូវបានចាត់ទុកថាជាមនុស្សល្អ គឺជាអ្នកដែលមានចិត្តនឹងនរ ចេះជួយទុក្ខធុរៈ និងមិនផឹកស្រា ។ ទាក់ទងទៅនឹងពាក្យ«ក្ដាប់ប្រជាជន» នួន ជា បានឲ្យដឹងថា បក្សកុម្មុយនីស្តកម្ពុជាមិនប្រើពាក្យ ការជម្លៀស«ដោយបង្ខំ»ទេ តែបានប្រើពាក្យ ការជម្លៀស«ដោយច្បាស់លាស់» ។ មិនច្បាស់ទេថា តើមកពីបញ្ហាបកប្រែដែលធ្វើឲ្យ នួន ជា ឆ្លើយមិនត្រូវសំណួរឬយ៉ាងណា ។ ក្រោយមក

នួន ជា បាននិយាយម្តងទៀតថា ប្រជាជនត្រូវបានជម្លៀសចេញ ព្រោះតែមានការគំរាមកំហែងពី "ជនមួយចំនួន" ដែលចង់គ្រប់គ្រងបដិវត្តន៍ ។

បន្តមក បាណាបេ ណេគូអឺ បានសួរអំពីសមាជិកម្នាក់របស់ចលនាកុម្មុយនីស្តខ្មែរវៀតណាម ឈ្មោះ ង្វៀន វ៉ាន់លីញ ។ នួន ជា បានបញ្ជាក់ថា ង្វៀន វ៉ាន់លីញ គឺជាមនុស្សស្មោះត្រង់ តែគាត់មិនមានមហិច្ឆតាគ្រប់គ្រងកម្ពុជាទេ ។ ង្វៀន វ៉ាន់លីញ ត្រូវបាន "បណ្តុះមនោគមន៍" ដោយមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តវៀតណាម ទោះបីជាគាត់ជាមនុស្សល្អក៏ដោយ ។

បញ្ហាជម្លោះត្រូវបានដោះស្រាយរវាងកុម្មុយនីស្តកម្ពុជា និងកុម្មុយនីស្តវៀតណាមតាមរយៈទំនាក់ទំនងជាបុគ្គលដែលគាត់បានសាងជាមួយ ង្វៀន វ៉ាន់លីញ តែទំនាក់ទំនងនេះមិនអាចគេចពីសង្គ្រាមបានឡើយ ។

បាណាបេ ណេគូអឺ បានសួរអំពីតួនាទីជាអ្នកដឹកនាំក្នុងអំឡុងពេលនៃសង្គ្រាមជាមួយ លន់ នល់ ។ ទាក់ទងទៅនឹងសំណួរនេះ នួន ជា បានឆ្លើយទៅនឹងសំណួរដដែលត្រង់ថា គាត់មានតួនាទីគ្រាន់តែ "ការអប់រំ" ប៉ុណ្ណោះ ។ គាត់មិនមាន "អំណាចយោធា" ទេនៅពេលនោះ ហើយអំណាចយោធា គឺជាភារកិច្ចរបស់លេខាភូមិភាគនីមួយៗដែលក្រោមការគ្រប់គ្រងផ្ទាល់ដោយ ប៉ុល ពត និង សុន សេន ។

បាណាបេ ណេគូអឺ បានឆ្លើយទៅវិញ អំពីការទទួលភារកិច្ចក្នុងការរក្សាសុវត្ថិភាពដល់សម្តេចសីហនុ ពេលដែលព្រះអង្គមកទតខេត្តសៀមរាបក្នុងឆ្នាំ១៩៧២ ។ នួន ជា បានឆ្លើយថា គាត់ទទួលខុសត្រូវមើលកិច្ចការសន្តិសុខពេលដែលព្រះអង្គមកទតខេត្តសៀមរាប ។ បាណាបេ ណេគូអឺ បានសួរ នួន ជា ថា តើគាត់អាចមានសិទ្ធគ្រប់គ្រងសន្តិសុខដោយមិនមានអំណាចបញ្ជាទាហានយ៉ាងម៉េចនឹងកើត? នួន ជា បានឆ្លើយថា គាត់មានកម្លាំងគ្រប់គ្រាន់សម្រាប់កិច្ចការសន្តិសុខនេះ តែគាត់មិនមានយោធានៅក្នុងដៃទេ ។

ក្រោយមក នួន ជា ត្រូវបានសួរអំពីគោលនយោបាយពិតប្រាកដរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងក្នុងឆ្នាំ១៩៧៥ ។ បាណាបេ ណេគូអឺ បានសួរថាតើព្រះសង្ឃត្រូវជម្លៀសចេញពីទីក្រុងទៅកាន់សហករណ៍ដែរឬយ៉ាងណា? នួន ជា បានបញ្ជាក់ថា ព្រះសង្ឃត្រូវបានបញ្ជូនទៅព្រៃ និងតំបន់ផ្សេងទៀត ។ បក្សកុម្មុយនីស្តកម្ពុជាមិនបិទវត្តអារាមទាំងអស់នោះទេ ហើយក៏មានអាចារ្យខ្លះដែរគង់នៅក្នុងវត្តដែរ ។

បាណាបេ ណេគូអឺ បាននិយាយថា នួន ជា ខ្លួនឯងគឺជាមនុស្សចាស់ ហើយមានសភាពខ្សោយនៅពេលនេះ មេធាវីរូបនោះបានសួរថា តើហេតុអ្វីបានជាមនុស្សចាស់ត្រូវបានជម្លៀសចេញពីទីក្រុងដើម្បីទៅធ្វើការនៅសហករណ៍? តើមនុស្សចាស់ត្រូវបានចាត់ទុកជាសត្រូវដែរឬទេ? នួន ជា

បានបដិសេធថា បក្សកុម្មុយនីស្តកម្ពុជាមិនដែលសង្ស័យទៅលើមនុស្សចាស់ទេ ហើយក៏មិនដែលបង្ខំមនុស្សចាស់ឲ្យធ្វើការហួសកម្លាំងដែរ ។ តែមនុស្សចាស់ត្រូវបានចាត់តាំងឲ្យធ្វើការល្មមៗតាមកម្លាំងរបស់គាត់ ។

បាណាបេ ណេគូអី បានបញ្ចប់ការសួរនាំ ហើយ ស៊ីវន ចាប់ផ្ដើមសួរសំណួរបន្ដទាក់ទងទៅនឹងការតស៊ូប្រដាប់អាវុធដោយបក្សកុម្មុយនីស្ដកម្ពុជាក្នុងឆ្នាំ១៩៦៨ ។ នួន ជា បានបញ្ជាក់ថា ការតស៊ូប្រដាប់អាវុធចាប់ផ្ដើមនៅសំឡូត ហើយហេតុផលដែលប្ដូរទៅរកការតស៊ូដោយអាវុធវិញព្រោះដោយសារតែ«អំពើជិះជាន់» ដែលបង្កឡើងដោយ លន់ នល់ ។

ក្រោយពី ស៊ីវន សួរចប់ ចៅក្រម និល ណុន បានសួរទៅក្រុមការពារក្ដីរបស់ អៀង សារី និង ខៀវ សំផន ថាតើមានចង់សួរទៅកាន់ជនជាប់ចោទ នួន ជា ដែរឬទេ? ក្រុមការពារក្ដីទាំងពីរបដិសេធមិនចង់សួរទេ ដូច្នេះចៅក្រមក៏ប្រគល់តួនាទីនេះទៅក្រុមការពារក្ដីរបស់ នួន ជា ដើម្បីសួរទៅកាន់កូនក្ដីរបស់ខ្លួន ។

## នួន ជា សួរដោយក្រុមការពារក្ដីរបស់ខ្លួន

មេធាវីអន្ដរជាតិ ម៉ៃឃើល ផេស្ដមែន បានសុំទៅចៅក្រមថានឹងសួរសំណួរទៅ នួន ជា នៅពេលក្រោយវិញដោយសារតែ នួន ជា អស់កម្លាំងជាមួយនឹងការឆ្លើយសំណួរច្រើនពេក ។ ចៅក្រម និល ណុន បានសួរទៅ នួន ជា ថាតើគាត់អាចឆ្លើយសំណួរទៀតបានដែរឬទេ? នួន ជា បានឆ្លើយថា គាត់«អស់កម្លាំង» តែគាត់អាចឆ្លើយ«ពីរបីសំណួរ» ព្រោះគាត់ចង់ជួយតុលាការដើម្បីស្វែងរកការពិត ។

មេធាវី ម៉ៃឃើល ផេស្ដមែន បានសួរថាតើ នួន ជា នៅទីណាមុននឹងទៅរៀននៅប្រទេសថៃ? នួន ជា បានឆ្លើយថា ម្ដាយរបស់គាត់គឺជាជាងដេរ ហើយឪពុកគឺជាអ្នកជួញដូរស្រូវអង្ករ ។ ជួនកាល ឪពុករបស់គាត់ត្រូវខ្ចីលុយពីអ្នកមាន នៅពេលដែលអ្នកទារលុយមកផ្ទះគាត់ម្ដងៗឪពុករបស់គាត់រត់ពួន ហើយម្ដាយគាត់យំ ។ ទោះបីជាមានបញ្ហាច្រើននៅក្នុងគ្រួសារក៏ដោយ ក៏ម្ដាយរបស់គាត់នៅតែជម្នះ និងឲ្យគាត់ទៅរៀនដែរ ។ ពេលដែលគាត់នៅក្មេង សង្គមកម្ពុជាគឺស្ថិតនៅក្នុងសម័យកាល«ពាក់កណ្ដាលអាណានិគម»និង«ពាក់កណ្ដាលទាសភាព» ។ កាលនោះស្ដ្រីត្រូវបានធ្វើបាប និងវាយដំដោយចៅហ្វាយនាយ ទោះបីជាចៅហ្វាយនាយនោះគឺជាមនុស្សថ្នាក់ក្រោមក៏ដោយ ដូចជា ក្រឡាបញ្ជីជាដើម ។ ក្រោយពីឃើញហេតុការណ៍ទាំងអស់នោះហើយ នួន ជា «មារអារម្មណ៍រន្ធត់» តែគាត់មិនចាប់អារម្មណ៍នឹងបញ្ហាសង្គមទេ ។ ក្រោយមក នួន ជា បាននិយាយថា គាត់បានបួសជាលោកនេន ។

នៅពេលដែលអដ្ឋាធរបារាំងចូលមកដល់ គាត់ស្នាក់នៅវត្ត ពេលនោះគាត់«ឃើញនូវការគាបសង្កត់ពីសំណាក់អាជ្ញាធរថៃ ដែលមកសម្លាប់ប្រជាជនកម្ពុជា» ។

ក្រោយមក នួន ជា បានទៅប្រទេសថៃដើម្បីរៀនសូត្រ មួយរយៈក្រោយមក គាត់បានបោះបង់ចោលការសិក្សា ព្រោះគាត់ជឿថា ជា«រឿងឥតប្រយោជន៍»ទេក្នុងការបន្តការសិក្សាបន្តទៀត ។ គាត់បានចូលធ្វើការរដ្ឋក្នុងប្រទេសថៃមុននឹងត្រលប់មកប្រទេសកម្ពុជាវិញ ។

ត្រង់ចំណុចនេះ នួន ជា ចាប់ផ្តើមពិភាក្សាអំពីបទពិសោធន៍របស់គាត់ក្នុងរបបខ្មែរក្រហមហើយគាត់បានរៀបរាប់ឈ្មោះអ្នកនយោបាយខ្មែរពីររូបដែលជាអតីតជនបដិវត្តន៍ ។ ទីមួយ គឺ ហេង សំរិន ដែលជាអ្នក«ក្រ» តែជាមនុស្ស«ល្អ» ។ ហេង សំរិន គឺជាអ្នកជូន នួន ជា ពីផ្ទះរបស់គាត់នៅភូមិភាគពាយ័ព្យឆ្ពោះទៅភាគខាងកើតនៃប្រទេស ជាកន្លែងដែលបក្សកុម្មុយនីស្តកម្ពុជារៀបចំមូលដ្ឋាន ។ ទីពីរ គឺទំនាក់ទំនងជាមួយ ជា ស៊ីម ។ នួន ជា បាននិយាយថា ជា ស៊ីម គឺជា«កសិករថ្នាក់កណ្តាល» គាត់បានរៀនជាមួយ នួន ជា ដែរ ។ ជួនកាល ជា ស៊ីម ខ្ចីលុយដើម្បីយកទៅរៀន ព្រោះគាត់ក្រណាស់នៅពេលនោះ ។ នួន ជា បាននិយាយទៀតថា តែគាត់មិនច្បាស់ទេថា ជា ស៊ីម កាន់មុខតំណែងអ្វីក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ ។

ក្រោយមក នួន ជា រៀបរាប់ពីទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងបក្សកុម្មុយនីស្តវៀតណាមម្តងទៀត ។ នួន ជា និយាយថា វៀតណាមជំទាស់មិនឲ្យកម្ពុជាតស៊ូដោយអាវុធទេ ហើយវៀតណាមចេះតែឈ្លោះប្រកែកជាមួយបក្សកុម្មុយនីស្តកម្ពុជាជានិច្ច ។ បក្សកុម្មុយនីស្តកម្ពុជាអាចជួយឧបត្ថម្ភខ្លួនបាន តែវៀតណាមចង់គ្រប់គ្រងទឹកដីកម្ពុជា ។ សូម្បីតែសព្វថ្ងៃនេះ ប្រជាជនវៀតណាមកំពុងតែចូលទឹកដីកម្ពុជា ។ ការទម្លាក់គ្រាប់បែករបស់អាមេរិកមកលើកម្ពុជាអស់រយៈពេល«២០០ថ្ងៃនិង២០០យប់» តែវៀតណាមនៅតែ«ព្រៃផ្សៃជាងមុន» និងជាងអាមេរិកទៅទៀត ព្រោះវៀតណាមមានបំណងចង់លេបទឹកដីកម្ពុជា ។ នួន ជា បានបញ្ជាក់ថា គាត់«មិនបារម្ភ»អំពីសុវត្ថិភាពផ្ទាល់ខ្លួនទេ គាត់មិនខ្លាចជាប់គុកទេ តែគាត់បារម្ភពីអនាគតរបស់កម្ពុជា ។ ត្រង់ចំណុចនេះ ចៅក្រម និល ណុន និយាយកាត់ ហើយបានស្នើទៅ នួន ជា ឲ្យឆ្លើយទៅនឹងអ្វីដែលបានសួរទៅបានហើយ ។ ចៅក្រម និល ណុន ហាក់បីដូចជាមានការធុញទ្រាន់ការដែល នួន ជា និយាយពីទំនាក់ទំនងរវាងកម្ពុជា និងវៀតណាម ។

ឆ្លើយតបទៅវិញ មេធាវី ដេស្តមែន បានសួរទៅ នួន ជា នូវសំណួរសាមញ្ញថា តើគាត់មានចង់បញ្ចេញយោបល់អ្វីទៀតដែរឬទេ? នួន ជា បានបន្តនិយាយនូវអ្វីដែលចៅក្រមបានបន្ទាក់គាត់និយាយថា គាត់បារម្ភពីអនាគតរបស់កម្ពុជា ។ ត្រង់ចំណុចនេះ ចៅក្រម និល ណុន បានកាត់ នួន

ជា មួងទៀត រួចណែនាំឲ្យជនជាប់ចោទនិយាយតែពីរង្វង់នៃប្រវត្តិមុននិងការកកើតកម្ពុជាប្រជាធិបតេយ្យបានហើយ ។ ចំណុចនេះធ្វើឲ្យអ្នកតាមដានសើច ។

នួន ជា ចាប់ផ្ដើមនិយាយម្ដងទៀត តែពេលដែលគាត់និយាយ ម៉ៃក្រូហ្វូនរបស់គាត់ត្រូវបានអាក់ពាក់កណ្ដាលទី ។ មេធាវី ផេស្ដមែន បានស្នើឲ្យ នួន ជា និយាយម្ដងទៀត តែហាក់បីដូចជាមានការភាន់ច្រឡំខ្លះ ព្រោះចៅក្រម និល ណុន ទើបតែណែនាំ នួន ជា ឲ្យនិយាយនូវអ្វីដែលគាត់ត្រូវបានសួរ ។ មេធាវី ផេស្ដមែន បានជូនដំណឹងទៅអង្គជំនុំជម្រះថា គាត់ចង់ឮនូវអ្វីដែល នួន ជា បាននិយាយ ព្រោះការដែលគាត់និយាយនោះមិនមានការបកប្រែទេ តែជាបញ្ហាបច្ចេកទេស ។

មុន និងបញ្ហានេះត្រូវបានដោះស្រាយ ចៅក្រម និល ណុន បានជូនដំណឹងថា ដំណើរការសម្រាប់ថ្ងៃនេះនិងត្រូវបញ្ចប់ដោយសារតែសាក្សី ប្រាក់ យុត បានបញ្ចប់សក្ខីកម្មរបស់គាត់មុនពេលកំណត់ ហើយជាការសម្យល្មមនិងបញ្ចប់នៅពេលនេះ ។ អង្គជំនុំជម្រះនឹងចាប់ផ្ដើមសក្ខីកម្មនៅថ្ងៃស្អែកទៀតនៅម៉ោង ៩:០០ ដោយមានលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាចូលខ្លួនមកធ្វើសក្ខីកម្ម ។

**-ចប់-**